# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**

លេខ ០២.កយ.សណន-២០០៥

# សេចក្តីណែនាំរួម

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល

**<u>សូមជម្រាបមក</u>**

**លោកប្រធាន អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត ក្រុង**

**លោកព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អមតុលាការខេត្ត ក្រុង**

**<u>កម្មវត្ថុ</u>:** សេចក្តីណែនាំអំពីការអនុវត្តមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

កន្លងមក ក្រសួងយុត្តិធម៌ និងតុលាការកំពូលបានពិនិត្យឃើញថា ការអនុវត្តមាត្រា៤៦ ស្តីពីអំពើរំលោភលើសេចក្តីទុកចិត្ត នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩០ មិនទាន់បានឯកភាពគ្នានៅឡើយ នៅតាមតុលាការទូទាំងប្រទេស ។ ម្យ៉ាងវិញទៀតចំពោះការបែងចែកវិវាទរដ្ឋប្បវេណី ដែលជាការមិនបំពេញតាមករណីយកិច្ចកើតចេញពីកិច្ចសន្យា និងអំពើដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្តកំពុងស្ថិតនៅជាបញ្ហាដែលទាមទារឱ្យមានការដោះស្រាយផងដែរ ។

ការរំលោភសេចក្តីទុកចិត្ត គឺជាអំពើគេបន្លំ ឬបំបាត់ រំលោភកាន់កាប់មួយចំណែក ឬទាំងអស់នូវទ្រព្យសម្បត្តិអ្នកដទៃ ដែលគេបានប្រគល់អោយខ្លួនអាស្រ័យដោយការជឿទុកចិត្តរបស់ម្ចាស់ទ្រព្យឬអ្នកកាន់កាប់ទ្រព្យដែលសង្ឃឹមថា ទទួលបានមកវិញនូវទ្រព្យសម្បត្តិ ឬលទ្ធផលនៃការងារណាមួយពីអ្នកទទួលនូវទ្រព្យទាំងនោះ ។

ដើម្បីជាមូលដ្ឋានសម្រាប់ការចោទប្រកាន់ និងការវិនិច្ឆ័យរឿងនិងការបែងចែកខាងវិវាទរដ្ឋប្បវេណី និងបទល្មើសរំលោភលើសេចក្តីទុកចិត្ត ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមធ្វើការណែនាំដល់តុលាការ និងអយ្យការខេត្ត-ក្រុង យកចិត្តទុកដាក់ពិចារណាលើសញ្ញាណគតិយុត្ត ដែលបានបញ្ញត្តិក្នុងមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចរៀបរាប់ខាងក្រោម ។

**ធាតុផ្សំនៃបទល្មើសរំលោភលើសេចក្តីទុកចិត្តមាន៖**

១-មានច្បាប់ចែង ឧទាហរណ៍ មាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល

២-ជនល្មើសមានចេតនាទុច្ចរិត គៃបន្លំ ឬបំបាត់ទ្រព្យដែលខ្លួនបានទទួលពោលគឺការមិនបានប្រគល់ឬបង្ហាញនូវទ្រព្យ ឬលទ្ធផលនៃការងារកើតឡើងដោយឆន្ទៈមិនប្រគល់ពិតប្រាកដ ដែលពុំមែនកើតឡើងដោយឧបសគ្គសត្យានុម័តនោះឡើយ ហើយត្រូវមានអំពើគៃបន្លំ ឬបំបាត់ទ្រព្យសម្បត្តិប្រព្រឹត្តដោយអ្នកទទួលបាននូវទ្រព្យសម្បត្តិតាមរយៈកិច្ចសន្យាដែលស្តែងឡើងក្រោមរូបភាពជាការមិនប្រគល់ ឬប្រគល់ តែបានបន្លំបរិមាណ ឬគុណភាពនៃទ្រព្យសម្បត្តិទាំងនោះ ។

៣-សម្ភារ ឬមុខសញ្ញា នៃបទរំលោភលើសេចក្តីទុកចិត្តរួមមាន៖

ទ្រព្យសម្បត្តិ ប្រាក់កាស ទំនិញគ្រប់ឯកសារដែលមានឬដែលចែងអំពីកាតព្វកិច្ច ឬភារដោះបន្ទុកដែលគេប្រកាសអោយដកខ្លួន ក្នុងលក្ខណៈជាការជួល ការតម្កល់ទុក ជាអាណត្តិជាការអោយប្រើ ឬ ដើម្បីការងារមានបៀវត្សឬគ្មានបៀវត្ស ដែលត្រូវប្រគល់អោយគេវិញ ឬធ្វើជាតំណាង ឬសម្រាប់ប្រើប្រាស់ ឬ ជាមុខការមានកំណត់ដែលម្ចាស់ទ្រព្យបានផ្ទុកផ្តាក់ទ្រព្យរបស់ខ្លួនអោយទៅភាគីម្ខាង ហើយភាគីម្ខាងបានទទួលទ្រព្យនេះដោយស្របច្បាប់តាមរយៈ

កិច្ចសន្យាប្រាំមួយប្រភេទគឺ កិច្ចសន្យាជួល កិច្ចសន្យាផ្ញើទុក កិច្ចសន្យាបញ្ចាំ កិច្ចសន្យាអោយខ្ចីប្រើ កិច្ចសន្យាអាណត្តិ និងកិច្ចសន្យាការងាររវាងកម្មករ និងនិយោជិត ឬ មិនមែនរវាងនិយោជិត និងកម្មករ និយោជិត ។

៤-មានការអន្តរាយ ពោលគឺខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិ ម្ចាស់ទីកន្លែង ឬ អ្នកកាន់កាប់ ដែលបានប្រគល់នូវទ្រព្យទាំងនោះ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល សូមរំលឹក និងសូមឱ្យលោកចៅក្រមពិចារណាឱ្យបានល្អិតល្អន់ចំពោះការមិនបានបំពេញករណីយកិច្ច ដែលកើតចេញពីកិច្ចសន្យារដ្ឋប្បវេណីផ្សេងទៀត ក្រៅពីប្រភេទកិច្ចសន្យាទាំង៦ ដែលបានលើកឡើងខាងលើ ដូចជាកិច្ចសន្យាលក់-ទិញ កិច្ចសន្យាខ្ចីបរិភោគ (ដូចជាកិច្ចសន្យាខ្ចីប្រាក់) កិច្ចសន្យាឱ្យឬប្រទានកម្ម ដែលភ្ជាប់ករណីយកិច្ច ទោះបីដោយមូលហេតុណាក៏ដោយ ដែលអ្នកទទួលបាននូវទ្រព្យមិនបានបំពេញករណីយកិច្ចប្រគល់ឱ្យទៅអ្នកប្រគល់វិញនូវទ្រព្យនោះមិនមែនជាអំពើគៃបន្លំ ឬបំបាត់ ដែលរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្តនោះឡើយ ។

ការធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិតាមរយៈអំពើណាមួយ ដែលមិនរួមផ្សំជាបទល្មើសរំលោភលើសេចក្តីទុកចិត្ត អាចជាបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអំពើនោះត្រូវបានចែងក្នុងច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូល នឹងមានវិធានការតាមផ្លូវច្បាប់ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ក្រសួងយុត្តិធម៌ និងតុលាការកំពូលសង្ឃឹមថា អស់លោកចៅក្រមនឹងយកចិត្តទុកដាក់បន្ថែមទៀតក្នុងការអនុវត្តឱ្យបានត្រឹមត្រូវនូវបញ្ញត្តិមាត្រា៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដើម្បីការពារសិទ្ធិរបស់ពលរដ្ឋជួយរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងបង្កើនការជឿជាក់របស់ពលរដ្ឋ និងអ្នកវិនិយោគលើប្រពន្ធ័តុលាការនិងច្បាប់របស់កម្ពុជា ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៥

**តុលាការកំពូល** | **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ឌិត មុន្ទី** | **អង្គ វង្សវឌ្ឍានា**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និង មហាអយ្យការ

-ឯកសារ-កាលប្បវត្តិ